សន្លឹកព័ត៌មានសហគមន៍៖ បន្ទុកលើរដ្ឋ

មនុស្សមួយចំនួនដែលដាក់ពាក្យសុំសិទ្ធិរស់នៅស្របច្បាប់ ឬសុំទិដ្ឋាការដើម្បីចូលមកសហរដ្ឋអាមេរិក ត្រូវតែឆ្លងកាត់ការធ្វើតេស្តបន្ទុកលើរដ្ឋ "Public Charge" ដើម្បីឱ្យមន្ត្រីអន្តោប្រវេសន៍សម្រេចចិត្តថាតើជនអន្តោប្រវេសន៍នោះ ទំនងជាពឹងផ្អែកលើលុយរដ្ឋាភិបាលសម្រាប់តម្រូវការជំនួយជាមូលដ្ឋាននាពេលអនាគតដែរឬអត់។ **ច្បាប់ថ្មីមួយស្តីពីបន្ទុកលើរដ្ឋនឹងចូលជាធរមាននៅថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2026** ។ សូមពិនិត្យមើលគេហទំព័ររបស់មជ្ឈមណ្ឌលច្បាប់នៃរដ្ឋអូរីហ្គិន ដើម្បីទទួលបានព័ត៌មានច្បាប់ថ្មីបំផុត នៅ https://oregonlawcenter.org/ ហើយរកមើលតាម https://pifcoalition.org/ សម្រាប់ព័ត៌មានថ្មីៗអំពីការផ្លាស់ប្តូរ ឬការជំទាស់ផ្នែកច្បាប់ណាមួយ។

គ្រួសារជនអន្តោប្រវេសន៍ត្រូវដឹងឱ្យច្បាស់ពីរបីយ៉ាង អំពីច្បាប់ថ្មីស្តីពីបន្ទុកលើរដ្ឋ ៖

1 មនុស្សភាគច្រើនមិនចាំបាច់ព្រួយបារម្ភអំពីច្បាប់បន្ទុកលើរដ្ឋនេះទេ

- បន្ទុកលើរដ្ឋ **មិនមែន** អនុវត្តចំពោះមនុស្សគ្រប់គ្នានោះទេ។
- ជាធម្មតាបន្ទុកលើរដ្ឋ អនុវត្តចំពោះតែអ្នកដែលដាក់ពាក្យសុំកាត LPR/សិទ្ធិរស់នៅស្របច្បាប់ តាមរយៈសមាជិកគ្រួសារ (សុំសិទ្ធិរស់នៅស្របច្បាប់តាមរយៈ"បងប្អូនធានា")។
- ប្រសិនបើអ្នកមានសិទ្ធិរស់នៅស្របច្បាប់រួចហើយ ហើយកំពុងស្នាក់នៅក្នុងសហរដ្ឋអាមេរិក **នោះច្បាប់បន្ទុកលើរដ្ឋ មិនប៉ះពាល់ដល់អ្នកទេ** (សូម្បីតែពេលអ្នកដាក់ពាក្យសុំបន្តសិទ្ធិរស់នៅស្របច្បាប់របស់អ្នកតទៅទៀតក៏ដោយ)។
- ប្រសិនបើអ្នកមិនមានបំណងសុំសិទ្ធិរស់នៅស្របច្បាប់តាមបងប្អូនធានានាពេលអនាគតដ៏ខ្លីខាងមុខនេះទេ **នោះបន្ទុកលើរដ្ឋ មិន ប៉ះពាល់ដល់អ្នកឥឡូវនេះទេ** ហើយក៏ប្រហែលជាមិនប៉ះពាល់ដល់អ្នកទៅថ្ងៃក្រោយដែរ។
- ប្រសិនបើអ្នកជាពលរដ្ឋមានសញ្ជាតិអាមេរិកាំងរួចហើយ **បន្ទុកលើរដ្ឋក៏មិនប៉ះពាល់ដល់អ្នកដែរ** ។
- ច្បាប់បន្ទុកលើរដ្ឋ **មិន** អនុវត្តចំពោះជនអន្តោប្រវេសន៍ជាច្រើនប្រភេទ។ **ការធ្វើតេស្តមើលថាអាចជាបន្ទុកលើរដ្ឋ មិនអនុវត្តចំពោះជនអន្តោប្រវេសន៍ដែលកំពុងដាក់ពាក្យសុំសិទ្ធិរស់នៅស្របច្បាប់តាមរយៈជា " ជនអន្តោប្រវេសន៍មនុស្សធម៌ " ដែលមានរួមមួយចំនួនដូចខាងក្រោមនេះ៖**

*ជនអៀសខ្លួន/អ្នកសុំសិទ្ធិជ្រកកោនផ្នែកនយោបាយ

*អ្នកដាក់សុំជាជនរងគ្រោះដោយអំពើហិង្សា VAWA

*អ្នកកាន់ទិដ្ឋាការ T/U

*និងមានច្រើនទៀត!

*អ្នកដាក់ពាក្យ និងអ្នកកាន់ TPS

*ជនអន្តោប្រវេសន៍ដែលមានលក្ខណៈសម្បត្តិជាជនរងគ្រោះដោយអំពើហិង្សា

*អ្នកដែលត្រូវបានលើកលែងទោសមួយចំនួន

*SIJS (ក្មេងអន្តោប្រវេសន៍ពិសេស)

*អ្នកចូលតាមប្រទេសគុយបា/ហៃទី

*SIV សម្រាប់សម្ព័ន្ធមិត្តអាហ្វហ្គានីស្ថាន និងអ៊ីរ៉ាក់

2 ជំនួយរដ្ឋមួយចំនួនអាចត្រូវបានគេយកមកពិចារណា

- សម្រាប់ជនអន្តោប្រវេសន៍ដែលដាក់ពាក្យសុំសិទ្ធិរស់នៅស្របច្បាប់ "តាមរយៈបងប្អូនធានា" មុនថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2026 មានតែជំនួយពីរដ្ឋដូចជា SSI, TANF និងការមើលថែរយៈពេលវែងនៅក្នុងស្ថាប័នមួយប៉ុណ្ណោះ ដែលនឹងត្រូវបានគេរាប់នៅក្នុងការធ្វើតេស្តបន្ទុកលើរដ្ឋ។ ជំនួយដែលទទួលបានដោយសមាជិកគ្រួសាររបស់ជនអន្តោប្រវេសន៍ នឹងមិនរាប់បញ្ចូលក្នុងការធ្វើតេស្តបន្ទុកលើរដ្ឋនេះឡើយ។
- ជនអន្តោប្រវេសន៍ដែលដាក់ពាក្យសុំសិទ្ធិរស់នៅស្របច្បាប់ "តាមរយៈបងប្អូនធានា" បន្ទាប់ពីថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2026 នឹងត្រូវស្ថិតនៅក្រោមច្បាប់ថ្មីបន្ទុកលើរដ្ឋ ។ រាល់ការឆែកមើល

«លុយកាក់ហិរញ្ញវត្ថុ» ទាំងអស់ដែលគេមាន (ជំនួយដែលមនុស្សម្នាក់មានសិទ្ធិទទួលបាន គឺដោយសារតែពួកគេមានប្រាក់ចំណូលទាប) ឬសមាជិកគ្រួសាររបស់ពួកគេមាន អាចត្រូវបានគេរាប់នៅក្នុងការធ្វើតេស្តបន្ទុកលើរដ្ឋនេះផងដែរ ។

3 បន្ទុកលើរដ្ឋនេះមិនមែនគ្រាន់តែទទួលសេវាកម្មពីរដ្ឋាភិបាលនោះទេ

- មន្ត្រីអន្តោប្រវេសន៍ត្រូវតែពិនិត្យមើលតាមកាល:ទេស: **ទាំងមូល** របស់បុគ្គលម្នាក់ៗ នៅពេលដែលពួកគេអនុវត្តការធ្វើតេស្តបន្ទុកលើរដ្ឋ មិនមែនគ្រាន់តែឆែកថាតើបុគ្គលនោះបានទទួលជំនួយពីកម្មវិធីរបស់រដ្ឋាភិបាលដែរឬអត់នោះទេ។
- សុខភាព សមត្ថភាពក្នុងការធ្វើការ និងស្ថិរភាពហិរញ្ញវត្ថុរបស់ជនអន្តោប្រវេសន៍ គឺជាកត្តាវិជ្ជមានដែលអាចជួយជនអន្តោប្រវេសន៍ក្នុងការធ្វើតេស្តមិនដាក់បន្ទុកលើរដ្ឋ ទោះបីជាពួកគេបានប្រើប្រាស់ជំនួយពីរដ្ឋ កាលពីអតីតកាលក៏ដោយ។

មានសំណួរអ្វីទេ? អ្នកមិនឯកាទេ។ អាចរកការពឹងពាក់បាន។

ប្រសិនបើអ្នកកំពុងដាក់ពាក្យសុំសិទ្ធិរស់នៅស្របច្បាប់ក្នុងពេលឥឡូវនេះ ឬនាពេលអនាគតដ៏ខ្លីខាងមុខដោយផ្អែកលើសមាជិកគ្រួសារ (បងប្អូនធានា) សូមពិគ្រោះជាមួយមេធាវីអន្តោប្រវេសន៍ ឬស្វែងរកដំបូន្មានផ្នែកច្បាប់អំពីបន្ទុកលើរដ្ឋនេះ។

- សូមទូរស័ព្ទទៅខ្សែទូរស័ព្ទទាន់ហេតុការណ៍របស់មជ្ឈមណ្ឌលច្បាប់នៃរដ្ឋ អូរីហ្គិន និងសេវាកម្មជំនួយផ្នែកច្បាប់នៃការទទួលជំនួយពីរដ្ឋអូរីហ្គិន តាមរយៈលេខ 1-800-520-5292។
- **តាមដានព័ត៌មាន** និងទទួលបានព័ត៌មានថ្មីៗ អំពីច្បាប់ស្តីពីបន្ទុកលើរដ្ឋ ដោយចូលទៅកាន់ https://pifcoalition.org/pc ។
- ព័ត៌មានលម្អិតបន្ថែមអំពីច្បាប់ស្តីពីបន្ទុកលើរដ្ឋអាចរកបាននៅ https://pifcoalition.org/resources/library/public-charge-what-advocates-need-to-know/
- ស្វែងរក បញ្ជីសេវាកម្មផ្នែកច្បាប់អន្តោប្រវេសន៍ថ្នាក់ជាតិ សម្រាប់សេវាកម្មផ្នែកច្បាប់ដែលឥតគិតថ្លៃ ឬមានតម្លៃទាប។
- ស្វែងរក មេធាវីអន្តោប្រវេសន៍ឯកជននៅក្នុងតំបន់របស់អ្នក។
- ប្រជាជនមួយចំនួនដែលរស់នៅរដ្ឋអូរីហ្គិនអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលសេវាកម្មផ្នែកច្បាប់អន្តោប្រវេសន៍ដោយឥតគិតថ្លៃតាមរយៈ Equity Corps of Oregon។ ស្វែងយល់បន្ថែម និងស្វែងរកជំនួយនៅ https://equitycorps.org/ ឬដោយទូរស័ព្ទទៅលេខ 1-888-274-7292។
- ស្វែងរកព័ត៌មានអំពីកម្មវិធីអាហារដោយឥតគិតថ្លៃនៅក្នុងរដ្ឋអូរីហ្គិន តាមរយៈ https://foodfinder.oregonfoodbank.org/ ឬដោយទូរស័ព្ទទៅលេខ 211។
- ស្វែងរកជំនួយជាមួយបញ្ហាផ្លូវច្បាប់ផ្សេងទៀតដូចជា លំនៅដ្ឋាន សុំសិទ្ធិមើលកូន ការលែងលះ ប្តឹងពីការងារ សិទ្ធិជនរងគ្រោះ ដីកាហាមឃាត់ និងច្រើនទៀត តាមរយៈ បញ្ជីសេវាកម្មផ្លូវច្បាប់មិនស្វែងរកប្រាក់ចំណេញរបស់ Oregon Law Help ឬ សេវារកមេធាវីពីគណៈមេធាវីប្រចាំរដ្ឋអូរីហ្គិន ។

Latino Network

Oregon Law Center
WORKING TOGETHER TO ACHIEVE JUSTICE FOR LOW INCOME OREGONIANS

Latino COMMUNITY ASSOCIATION